long beach unified school district

**LONG BEACH UNIFIED SCHOOL DISTRICT**

# ក្រុមប្រឹក្សា Board of Education នឹងសើរើមើលគម្រោងការណ៍នៃច្បាប់សរសេរព្រាងទុកសំរាប់ប្រើថវិការ

*សូមអានមើលនៅទីនេះអំពីការរៀបរាប់គម្រោងការណ៍ពេញលេញ ជាភាសា អង់គ្លេស, អេស្ប៉ាញ៉ូល និង ខ្មែរ*

នៅក្នុងកម្មវិធីប្រជុំធម្មតានៅ ថ្ងៃទី3 ខែមិថុនា គឺក្រុមប្រឹក្សា Board of Education នៃក្រសួងអប់រំ ឌីស្ទ្រីគ ឡុងប៊ីច នឹងសើរើមើលអំពីគម្រោងការណ៍នៃច្បាប់សរសេរព្រាងទុកសំរាប់ប្រើតាមរូបមន្តថ្មីរបស់រដ្ឋ ដែលទាក់ទងការចែកផ្តល់ថវិការសំរាប់សាលារៀន ។ គ្មានការសម្រេចផ្តល់សម្លេងបោះឆ្នោតអ្វីទេមកលើគម្រោងការណ៍នៅក្នុងកម្មវិធីប្រជុំនេះ ។

គម្រោងការណ៍ គឺជាចម្លើយទៅកាន់ការទទួលយល់ព្រមរបស់រដ្ឋស្តីអំពីរូបមន្តចែកផ្តល់ថវិការម្យ៉ាងហៅ Local Control Funding Formula (LCFF) សំរាប់សាលារៀន ។ រូបមន្តថ្មីនេះនឹងប្រើជំនួសរូបមន្តហួសសម័យ ដែលមានការភ័ន្តច្រើនអំពីការចែកផ្តល់ថវិការទៅកាន់សាលារៀន ហើយនេះជារូបមន្តមួយ ដែលផ្តល់ភាពងាយជាងសំរាប់ប្រើថវិការពីរដ្ឋ ដោយសំអាងលើសេចក្តីត្រូវការរបស់សិស្ស ។

ក្នុងពេលថ្មីៗនេះ ... បន្ទាប់ពីបានទទួលការយល់ព្រមដោយរដ្ឋអំពីរូបមន្តថ្មីពីឆ្នាំកន្លងមក គឺក្រសួងអប់រំ ឌីស្ទ្រីគ ឡុងប៊ីច LBUSD បានប្រឹងបើកផ្លូវបង្កើតទំនាក់ទំនងជាមួយសហគមន៍ ដើម្បីរៀបចំគម្រោងការគ្រប់គ្រង និង ទទួលខុសត្រូវប្រចាំតំបន់ - Local Control and Accountability Plan (LCAP) ។ ការសរសេរព្រាងទុកនៃ LCAP គឺបញ្ជាក់អំពីចំណែកសំខាន់និមួយៗមុនគេ ដែលនឹងចំណាយថវិការមកលើ និង រង្វាស់ទទួលខុសត្រូវ ដើម្បីបញ្ជាក់ថា ជំនួយផ្សេងៗ គឺបានប្រើត្រឹមត្រូវមែន ។ ក្រុមប្រឹក្សា Board of Education អាចថ្លឹងថ្លែងមើលអំពីគម្រោងការណ៍នេះ សំរាប់ជាការទទួលស្គាល់ស្របច្បាប់នៅថ្ងៃទី17 ខែមិថុនា ។

ក្នុងការរៀបចំគម្រោងការណ៍ គឺក្រសួងអប់រំ ឌីស្ទ្រីគ បានទទួលជាង 2,700 ចម្លើយមកវិញពីការស្ទង់មតិ ដែលបានរាយផ្សាយទៅកាន់សហគមន៍ និង ក្រុមប្រឹក្សា LCAP នៃក្រសួងអប់រំ ឌីស្ទ្រីគ ដែលមានសមាជិកជាង 66 នាក់មកពីគ្រប់ឋានៈទាំងអស់ បានជួបជុំគ្នាចំនួន បួន លើក ដើម្បីពិគ្រោះដោះស្រាយអំពីចំណែកសំខាន់និមួយៗ (មានទាំងអស់ ប្រាំបី ចំណែក) របស់រដ្ឋ ដែលត្រូវគិតគូរមុនគេ និង សើរើមើលអំពីការចំណាយផ្សេងៗ ។ ប្រាំបី ចំណែកសំខាន់របស់រដ្ឋ គឺមានជាៈ ផលចម្រើនសំរាប់សិស្ស, ទំនាក់ទំនងជាមួយសិស្ស, ទំនាក់ទំនងជាមួយមាតាបិតា, ការរៀបចំទូទៅនៅក្នុងសាលារៀន, ការប្រើតាមខ្នាតគំរូនៃមេរៀនបង្ហាត់ស្រដៀងគ្នា (Common Core Standards) , ការបើកបង្កើតថ្នាក់បន្ថែមជាច្រើន, ជំនួយចាំបាច់ទូទៅ និង លទ្ធផលផ្សេងៗទៀតសំរាប់សិស្ស ។ ក្រុមប្រឹក្សាបានលើកផ្តល់សេចក្តីអនុសាសន៍ទៅកាន់ Board of Education នៅខែកុម្ភៈ ។ សេចក្តីអនុសាសន៍ទាំងអស់នោះបានរាប់បញ្ចូលទៅក្នុងគម្រោងការណ៍សរសេរព្រាងទុក បន្ទាប់ពីមានកម្មវិធីប្រជុំ បី/បួន លើកកន្លងមកជាមួយក្រុមច្រើនចំណែកនៅតាមសហគមន៍ ។

គម្រោងការណ៍សរសេរព្រាងទុក គឺផ្តល់ជំនួយបន្ថែមមកកាន់សាលារៀនទាំងអស់នៅក្នុងក្រសួងអប់រំ ឌីស្ទ្រីគ, ជាពិសេស គឺសំដៅលើសាលារៀនទាំងឡាយណា ដែលត្រូវការជំនួយខ្លាំងជាងគេ ឬ មានចំនួនសិស្សជាច្រើននាក់មកពីក្រុមគ្រួសារមានប្រាក់ចំណូលតិច, សិស្សកំពុងរៀនភាសាអង់គ្លេស និង សិស្ស ដែលត្រូវបានមនុស្សធំផ្សេងជ្រើសយកចិញ្ចឹម ។ គម្រោងការណ៍ គឺរាប់បញ្ចូលផងទាំងបញ្ជីរៀបរាប់កិច្ចការបម្រុងរៀបចំធ្វើ ដែលនឹងមានជាបន្តបន្ទាប់គ្នាក្នុងរយៈពេល បី ឆ្នាំទៅមុខសំរាប់ភាពលូតលាស់ជាបន្ត ។ តទៅនេះ គឺជាការបង្ហាញកិច្ចការរៀបចំធ្វើនៅតាមឆ្នាំសិក្សាៈ

**2014-15**

• បង្កើនចំនួនបន្ទប់រៀនសំរាប់បង្ហាត់អក្សរកម្រិតថ្នាក់ទី បី នៅតាមសាលារៀនផ្សេងៗ ដែលត្រូវការជំនួយខ្លាំងជាងគេ

• បង្កើនកម្មវិធីបង្ហាត់ដន្ត្រីនៅតាមសាលាបឋមសិក្សាក្នុងក្រសួងអប់រំ ឌីស្ទ្រីគ ទាំងមូល

ដោយបូកបន្ថែមកម្មវិធីបង្ហាត់ឧបករណ៍ដន្ត្រីសំរាប់កម្រិតថ្នាក់ទី បី

• បង្កើនកម្មវិធីអប់រំផ្នែកលើកទឹកចិត្តសំរាប់សិស្សនៅតាមសាលាបឋមសិក្សា និង កម្រិត K-8 ដែលត្រូវការជំនួយខ្លាំងជាងគេ

- បង្កើនកម្មវិធីព្យាបាលជម្ងឺទូទៅសំរាប់សិស្សនៅតាមសាលារៀន
- បង្កើនកម្មវិធីសិក្សាផ្នែកបណ្ណាល័យសំរាប់សិស្សនៅតាមសាលាបឋមសិក្សា ដែលត្រូវការជំនួយខ្លាំងជាងគេ និង ជួលបុគ្គលិកជំនួយបន្ថែមមកធ្វើការនៅក្នុងបណ្ណាល័យតាមសាលារៀន high school
- បង្កើនកម្មវិធីអប់រំផ្លូវចិត្តសំរាប់សិស្ស, ក្រោមការគ្រប់គ្រងរបស់អ្នកចិត្តសាស្ត្រ (psychologist)
- បង្កើនទំនាក់ទំនងជាមួយសិស្សភាគតិចស្តីអំពីការចុះឈ្មោះយកថ្នាក់ Advanced Placement
- រក្សាទុកចំនួនថវិការសំរាប់ប្រើគាំទ្រមកលើកម្មវិធីម៉្យាងហៅ Linked Learning ដែលប្រើថ្នាក់, កម្មវិធីហ្វឹកហ្វឺនផ្នែកអាជីវកម្ម និង មេរៀនធ្វើកិច្ចការផ្ទាល់ដៃ ដើម្បីពន្យល់សិស្សអំពីទំនាក់ទំនងរវាងសាលារៀន high school, មហាវិទ្យាល័យ និង មុខរបរត្រឹមត្រូវទៅថ្ងៃមុខ
- រក្សាទុកចំនួនថវិការសំរាប់ប្រើជាមួយបច្ចេកវិជ្ជា និង ការជួសជុល កុំព្យូទ័រ សំរាប់ប្រើប្រាស់បន្ត
- បើកឱកាសផ្តល់កម្មវិធីហ្វឹកហ្វឺនថ្មីស្តីអំពីការអប់រំ/បំពត់ ដែលសង្កត់មកលើភាពយុត្តិធម៌
- ផ្តល់កម្មវិធីហ្វឹកហ្វឺនបន្ថែមសំរាប់មាតាបិតា/ធ្វើទំនាក់ទំនងជាមួយសាលារៀន ដែល*គ្មាន*ជំនួយ Title I (non-Title I schools)
- ផ្តល់ជំនួយបន្ថែមសំរាប់គាំទ្រថ្នាក់ Advanced Placement និង ថ្នាក់បង្ហាត់មុខរបរច្បាស់លាស់
- ផ្តល់ជំនួយគាំទ្រមកកាន់ក្រុម Male Academies និង Female Academies ... កម្មវិធីទាំង ពីរ នេះជួយសិស្សដឹកនាំនៅតាមសាលារៀន high school អំពីការអប់រំសិស្សផ្សេងៗឲ្យគេចខ្លួនឆ្ងាយពីអំពើ ហ្គេង និង ការប្រើអំពើឃោឃៅ

**2015-16**

- ពង្រីកចំនួនបន្ទប់រៀនសំរាប់បង្ហាត់អក្សរកម្រិតថ្នាក់ទី ពីរ នៅតាមសាលារៀន ដែលត្រូវការជំនួយខ្លាំងជាងគេ
- ពង្រីកចំនួនបន្ទាប់រៀនសំរាប់បង្ហាត់អក្សរនៅតាមសាលារៀនផ្សេងៗ សូម្បីតែសាលារៀនទាំងអស់នោះមិនទាន់ត្រូវការជំនួយខ្លាំងក៏ដោយ
- បង្កើនកម្មវិធីបង្ហាត់ដន្ត្រីនៅតាមសាលាបឋមសិក្សាសំរាប់កម្រិតថ្នាក់ទី បួន និង ប្រាំ
- បង្កើនកម្មវិធីអប់រំផ្នែកលើកទឹកចិត្តសំរាប់សិស្សនៅតាមសាលាបឋមសិក្សា និង កម្រិត K-8
- បង្កើនកម្មវិធីព្យាបាលជម្ងឺទូទៅសំរាប់សិស្សនៅតាមសាលារៀន
- បង្កើនកម្មវិធីសិក្សាផ្នែកបណ្ណាល័យសំរាប់សិស្សនៅតាមសាលាបឋមសិក្សា ដែលត្រូវការជំនួយខ្លាំងជាងគេ និង ជួលបុគ្គលិកជំនួយបន្ថែមមកធ្វើការនៅក្នុងបណ្ណាល័យតាមសាលារៀន high school
- បង្កើនកម្មវិធីអប់រំផ្លូវចិត្តសំរាប់សិស្ស, ក្រោមការគ្រប់គ្រងរបស់អ្នកចិត្តសាស្ត្រ (psychologist)
- រក្សាទុកចំនួនថវិការ ដើម្បីបើកកម្មវិធីផ្តល់ព័ត៌មានរដូវក្តៅសំរាប់សិស្សថ្នាក់ទី ប្រាំបួន ទាំងអស់

• រក្សាទុកចំនួនថវិការសំរាប់ប្រើជាមួយបច្ចេកវិជ្ជា និង ការជួសជុល កុំព្យូទ័រ សំរាប់ប្រើប្រាស់បន្ត

• រក្សាទុកចំនួនថវិការសំរាប់ប្រើគាំទ្រមកលើកម្មវិធីម៉្យាងហៅ Linked Learning

• រក្សាចំនួនថវិការសំរាប់បើកកម្មវិធីបង្ហាត់មេលេខនៅរដូវក្តៅសំរាប់សិស្សរៀននៅតាមសាលាមធ្យមសិក្សា

• រក្សាចំនួនថវិការសំរាប់ការជួសជុល

**2016-17**

• ពង្រីកចំនួនបន្ទប់រៀនសំរាប់បង្ហាត់អក្សរកម្រិតថ្នាក់ទី មួយ នៅតាមសាលារៀន ដែលត្រូវការជំនួយខ្លាំងជាងគេ

• បង្កើនកម្មវិធីអប់រំផ្នែកលើកទឹកចិត្តសំរាប់សិស្ស

• បង្កើនកម្មវិធីសិក្សាផ្នែកបណ្ណាល័យសំរាប់សិស្សនៅតាមសាលាបឋមសិក្សា, K-8 និង មធ្យមសិក្សា

• បង្កើនកម្មវិធីអប់រំផ្លូវចិត្តសំរាប់សិស្ស, ក្រោមការគ្រប់គ្រងរបស់អ្នកចិត្តសាស្រ្ត (psychologist)

• រក្សាទុកចំនួនថវិការ ដើម្បីបើកកម្មវិធីផ្តល់ពត៌មានរដូវក្តៅសំរាប់សិស្សថ្នាក់ទី ប្រាំបួន ទាំងអស់

• រក្សាទុកចំនួនថវិការសំរាប់ប្រើគាំទ្រមកលើកម្មវិធីម៉្យាងហៅ Linked Learning

• រក្សាទុកចំនួនថវិការសំរាប់ប្រើជាមួយបច្ចេកវិជ្ជា និង ការជួសជុល កុំព្យូទ័រ សំរាប់ប្រើប្រាស់បន្ត

សូមរៀនចំណាំបន្ថែមអំពីរូបមន្ត Local Control Funding Formula តាមរយៈ A-Z index នៅក្នុង គេហទំព័រ lbschools.net ។